# ហៅទូរស័ព្ទម្តង ចុចម្តង និង ចូលទៅទស្សនាម្តង

# TACOMA FIRST 311

**TacomaFirst** *(ក្រុមការងារផ្តល់សេវាប្រភពព័ត៌មានរហ័ស)* **ផ្នែកសេវាគាំទ្រអតិថិជន** ផ្តល់ជូនអ្នកនូវអារម្មណ៍យកចិត្តទុកពីសំណាក់បុគ្គលិកសេវាបម្រើអតិថិជន សេវាទំនាក់ទំនងជួបផ្ទាល់ និងសេវាគាំទ្រតាមទូរស័ព្ទ និងអនឡាញ។ វាមានទីតាំងនៅជាន់ទី 2 នៃអគារទីក្រុង Tacoma *(747 Market St.)* និងបើកបម្រើការងារ ពីថ្ងៃចន្ទ ដល់ សុក្រ ពីម៉ោង 8 ព្រឹក ដល់ម៉ោង 5 ល្ងាច លើកលែងតែថ្ងៃសម្រាកបុណ្យជាតិដែលទីក្រុងគោរពតាម។

---

ហៅទូរស័ព្ទទៅលេខ 311 ពីទូស័ព្ទប្រើខ្សែ ឬឧបករណ៍ចល័តមួយ។ 311 គឺជាលេខទូរស័ព្ទទីស្នាក់ការកណ្តាលដែលផ្តល់សេវាគាំទ្រផ្ទាល់ និងសេវាសារជាសំឡេងបន្ទាប់ពីម៉ោងធ្វើការធម្មតា សម្រាប់អ្នកហៅទូរស័ព្ទចូលដើម្បីស្វែងរកសេវានានារបស់ទីក្រុង។

---



ដាក់ និងតាមដានសំណើសុំសេវាទីក្រុងរបស់អ្នកតាមអនឡាញ និងស្វែងរកចម្លើយសម្រាប់សំណួរដែលទាក់ទងនឹងគោលនយោបាយ និងកម្មវិធីនានារបស់ទីក្រុង។

---

## កម្មវិធីទូរស័ព្ទដៃ

កម្មវិធីទូរស័ព្ទដៃ Tacoma FIRST 311 គឺអាចទាញយកមកប្រើប្រាស់ដោយឥតគិតថ្លៃនៅលើឧបករណ៍ចល័តប្រើប្រព័ន្ធប្រតិបត្តិការរបស់ក្រុមហ៊ុន Apple ឬប្រើប្រព័ន្ធប្រតិបត្តិការ Android (ប្រើ version 2.1 ឬខ្ពស់ជាងនេះ) និងផ្តល់លទ្ធភាពចូលទៅប្រើប្រាស់យ៉ាងរហ័ស និងងាយស្រួល នូវសេវាមិនមែនបន្ទាន់នានារបស់ទីក្រុង Tacoma។ ដាក់សំណើជាង 70 ប្រភេទ តាម៉ដានពីដំណើរការវិវត្តនៃសំណើរបស់អ្នកជាមួយនឹងគណនីអតិថិជនមិនគិតថ្លៃមួយ និងស្វែងរកចម្លើយទៅនឹងសំណួរជាទូទៅជាង 700។

### ការណែនាំពីការទាញយកកម្មវិធី

1. A. បើអ្នកប្រើប្រាស់ឧបករណ៍ចល័តប្រើប្រព័ន្ធប្រតិបត្តិការ Android ត្រូវប្រាកដថាអ្នកកំពុងប្រើ verson 2.1 ឬខ្ពស់ជាងនេះ ហើយបើកកម្មវិធី Google Play Store នៅលើទូរស័ព្ទ ឬ ថេបប្លេតរបស់អ្នក ដែលប្រើប្រព័ន្ធប្រតិបត្តិការ Android ឬចូលផ្ទាល់ទៅកាន់៖ **cityoftacoma.org/311appAndroid**

   B. បើអ្នកប្រើប្រាស់ឧបករណ៍ចល័តប្រើប្រព័ន្ធប្រតិបត្តិការរបស់ក្រុមហ៊ុន Apple សូមបើកកម្មវិធី App Store នៅលើទូរស័ព្ទ iPhone ឬ iPad របស់អ្នក ឬចូលផ្ទាល់ទៅកាន់៖ **cityoftacoma.org/311appApple**

2. ស្វែងរក "**TacomaFIRST**" ហើយឡូហ្គោគួរតែមើលទៅដូច៖

3. ចុចប៊ូតុង "Install" ដើម្បីទាញយក និងដំឡើងកម្មវិធី។

Tacoma

ស្វែងយល់បន្ថែមនៅគេហទំព័រ **cityoftacoma.org/tacomafirst**